00315209

E1/13

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 04 / 2009
ម៉ោង (Time/Heure): 11 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃដំណើរការនីតិវិធីនៃសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿងលេខ ០០១

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៩-ថ្ងៃទីប្រាំបួន

**សាធារណៈ**

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង **Natacha Wexels-Riser**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក លឹម ស៊ុយហុង, លោក Crippa MATTEO,លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក យ៉េត ចរិយា(ព្រឹក) លោក តាន់ សេណារ៉ុង(ល្ងាច), លោក Alexander Bates,លោក ពេជ្រ សម្បត្តិ,លោក ប៉ាក ចន្ទលីណូ,លោក Stuart Ford |

| |
|---|
| ជនជាប់ចោទ៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក Francois Roux,លោក ការ សាវុត្ថ, លោកស្រី Heleyn Unac,លោក ផាន់ វ៉ាវុធ,កញ្ញា Lucile Nattiez ,កញ្ញា Virginie CHARPENTIER(ល្ងាច)។ |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖លោក គង់ ពិសី,លោក យុង ផានិត, លោក ហុង គឹម សួន,កញ្ញា Silke Studzinsky,កញ្ញា ទី ស្រីនណា,កញ្ញា ម៉ុច សុវណ្ណារី,លោក Philippe Canonne,លោក Alain Werner លោក Karim A.A.Khan |
| មន្រ្តីតុលាការ/អង្គភាពគ្រប់គ្រងតុលាការ៖ លោក ខូវ កែវរតនៈ |
| ផ្នែកផ្សេងៗ៖ លោក Scott Bywater, កញ្ញា Julie Masse, លោក សាន គីរី, លោកស្រី Maryvonne Maniacky |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃ ទី ២១ ខែមេសា ឆ្នាំ ២០០៩ ព្រឹក | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាក អាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | **៤ ម៉ោង និង ៥៥នាទី** |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| បន្តតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.៥៦ |
| ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយសហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ០៩.៥៦ | ១១.២០ |
| ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១,២,៣ និងក្រុមទី៤ | ១១.២០ | ១៥.៤៦ |
| សំណើក្នុងការយោងទៅលើឯកសារលេខ D59 ឧបសម្ព័ន្ធទី១ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ | ១៣.៥៥ | |

| | | | |
|---|---|---|---|
| សំណើក្នុងការយោងទៅលើឯកសារលេខ ១៩.២៥ ឧបសម្ព័ន្ធ C នៃសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ | សហព្រះរាជអាជ្ញា | ១៤.៤៣ | ១៤.៤៥ |
| ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយមេធាវីការពារក្ដី | មេធាវីការពារក្ដី | ១៥.៤៧ | ១៦.១៩ |
| | | | |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖**

**ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយអង្គជំនុំជម្រះ**

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅសាក្សី ចាន់ ខន(KW-32)ទាក់ទងនឹងអង្គហេតុមន្ទីរ ម១៣
- អង្គជំនុំជម្រះបានសួរតទល់ជនជាប់ចោទជាមួយនឹងសក្ខីកម្មរបស់សាក្សី

**ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយសហព្រះរាជអាជ្ញា**

- សហព្រះរាជអាជ្ញាបានតាំងសំណួរទៅសាក្សីចាន់ខន(KW-32)ទាក់ទងនឹងមន្ទីរម១៣ ហើយបានអានបន្ថែមនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សី ចាន់ខន(KW-32) (ឯកសារលេខD78/4)។
- សហព្រះរាជអាជ្ញាបានសួរតទល់ជនជាប់ចោទជាមួយនឹងសក្ខីកម្មរបស់សាក្សី ។

**ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ បានតាំងសំណួរទៅសាក្សី ចាន់ខន(KW-32) ទាក់ទងនឹងមន្ទីរម១៣ ហើយបានសួរទៅជនជាប់ចោទទាក់ទងនឹងមន្ទីរម១៣ ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី២ បានតាំងសំណួរទៅសាក្សី ចាន់ខន(KW-32) ទាក់ទងនឹងមន្ទីរម១៣ ហើយបានស្នើសុំអង្គជំនុំជម្រះក្នុងការលើកយកឯកសារលេខD59 ឧបសម្ព័ន្ធទី១ (បទសម្ភាសន៍ជាមួយលោកចាន់ខន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា)។ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ បានគាំទ្រចំពោះសំណើនោះ ។
- មេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ម្ដងទៀតថាមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនជាស្ថាប័នយុត្តិធម៌ និងគ្មានការធានាផ្នែកនីតិវិធីទាក់ទងនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

នោះទេ និងបានជំទាស់ចំពោះការប្រើប្រាស់ឯកសារនេះ ។

- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានស្នើសុំឱ្យមានសេចក្តីសម្រេចទូទៅមួយទាក់ទងនឹងការប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។
- អង្គជំនុំជម្រះបានសម្រេចឱ្យភាគីទាំងអស់អាចយោងទៅលើឯកសារដែលមានលេខD59 ឧបសម្ព័ន្ធទី១ យកមកដេញដោលនៅពេលសវនាការបាន។
- សហព្រះរាជអាជ្ញាបានស្នើសុំក្នុងការអនុញ្ញាតិប្រើប្រាស់ឯកសារលេខ ១៩.២៥ (ឧបសម្ព័ន្ធ C នៃសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "របាយការណ៍លេខ ៦៥ ផ្នែក ស៊ីប្រា ពីអ្នកយកការណ៍ ឈ្មោះ ឈឹន សុទ្ធី ហៅ សារិន ដែលបានចុះចូលក្រៅការប្រយុទ្ធកាលពីថ្ងៃទី ១៥ ធ្នូ ឆ្នាំ ១៩៧៥") ។
- អង្គជំនុំជម្រះបានបដិសេធចំពោះការស្នើសុំ ហើយបានចង្អុលបង្ហាញថាអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចំពោះបញ្ហានេះនៅពេលក្រោយ។ ហើយអង្គជំនុំជម្រះបានស្នើឱ្យភាគីទាំងអស់ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ចំពោះបញ្ហានេះនៅព្រឹកស្អែក។
- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានតាំងសំណួរទៅសាក្សីទាក់ទងនឹងមន្ទីរម១៣ និងបានអានបន្ថែមពីឯកសារ D78/4 ព្រមទាំងបានតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី។

**<u>ការតាំងសំណួរទៅសាក្សី ចាន់ ខន (KW-32) ដោយមេធាវីការពារក្តី</u>**

- មេធាវីការពារក្តីបានតាំងសំណួរទៅសាក្សី ចាន់ខន (KW-32) ទាក់ទងនឹងមន្ទីរម១៣ និងបានផ្តល់ឱកាសដល់ជនជាប់ចោទក្នុងការលើកឡើងទាក់ទងនឹងសាក្សី ។
- ជនជាប់ចោទបានលើកឡើងថាគាត់មានចេតនាក្នុងការសរសេរលិខិតក្នុងការសុំខមាលទោសពីជនរងគ្រោះនៅអមលាំងនោះ ។

**<u>កំណត់ហេតុនៃដំណើរការនីតិវិធី វិធាន ៨៧៖</u>**

| លេខយោង | ឈ្មោះ/សេចក្តីអត្ថាធិប្បាយ | ផ្សេងៗ |
|---|---|---|
| E3/10 | បទសម្ភាសន៍ជាមួយលោកចាន់ ខន (KW-32) ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា | D59 ឧបសម្ព័ន្ធ១ |

| **ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖** |
| --- |
| -អង្គជំនុំជម្រះបានសម្រេចឱ្យភាគីទាំងអស់អាចយោងទៅលើឯកសារលេខ D59 ឧបសម្ព័ន្ធ១ ។<br>-អង្គជំនុំជម្រះបានបដិសេធក្នុងការប្រើប្រាស់ឯកសារលេខ ១៩.២៥ (ឧបសម្ព័ន្ធ C នៃសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"របាយការណ៍លេខ ៦៥ ផ្នែក ស៊ីប្រា ពីអ្នកយកការណ៍ ឈ្មោះ ឈឹន សុទ្ធី ហៅ សារិន ដែលបានចុះចូលក្រៅការប្រយុទ្ធកាលពីថ្ងៃទី ១៥ ធ្នូ ឆ្នាំ ១៩៧៤") ។<br>-ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៩ ។ |

| **ដីកាសម្រាប់ការលើកពេលសវនាការ៖** |
| --- |
| ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃស្អែក ទី ២២ ខែមេសា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ព្រឹក ។ |

ភ្នំពេញ, ថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុល ទុន្នី** **Natacha Wexels-Riser**